# ម្ដេចចោលពុទ្ធសាសន៍?

(បទកាកគតិ)

សំនេរកវី តាក់តែងកាព្យថ្មី ចារលើដីចាស់
សម្បត្តិវប្បធម៌ ជំនឿពុទ្ធសាសន៍ កូនខ្មែរដេរដាស
ធ្លាប់ស្គាល់គ្រប់គ្នា។

ព្រះពុទ្ធសាសនា ចាំជាប់ចិន្ដា តាំងពីយូរយា
ខ្លះស្គាល់តែឈ្មោះ មិនយល់ធម្មា ខ្លះមានសទ្ធា
តែមិនយល់ន័យ។

ខ្លះគួរអនិច្ចា កើតជាខេមរា សាសនាប្រពៃ
បោះបង់ស្រលះ កាន់សាសន៍ដទៃ បន្ទាបតំលៃ
ត្រៃរ័ត្នឧត្ដម។

ធ្វើឫកក្អេងក្អាង វង្វេងមិនស្ទាង ក្រអឺតហាក់ហំ
មិនខ្មាស់ខ្លួនឯង ខែងព្រោះច្រឡំ ចុះចាញ់មនោគមន៍
ភ្លេចពិចារណា។

អ្នកខ្លះទៀតសោត ចេះហើយនៅឆោត បោះបង់សាស្ដា
ធ្វើត្រាប់អ្នកល្ងង់ លង់លាភសក្ការ ហ៊ានលក់សិរសា
យកដុល្លារឡាន។

ព្រោះហេតុអ្វីទៅ ទើបបង់ជម្រៅ ជំនឿកល្យាណ
រឿងហ្នឹងកើតព្រោះ មិនជ្រាបលំអាន ឱវាទថ្លើងថ្កាន
នៃពុទ្ធសាសនា។

មិនគិតលកលៃ រកគុណប្រពៃ រកន័យខ្លឹមសារ
ម៉្លោះហើយអ្នកក្រៅ ស្រួលផ្ដុំសោតា បង្វិលចិន្ដា
បានតាមចិត្តនឹក។

ជាខ្មែរមួយជាតិ មិនត្រូវភ្ញាត់ស្មៀត អោយគេពង្វឹក
យើងជាតិអ្នកជា នាំគ្នារលឹក នឹងមិនធ្លាក់ទឹក

| | | |
|---|---|---|
| | ភ្លឹកតាមសាសន៍គេ។ | |
| គិតអោយច្បាស់មើល៍ | ស្រាវតាមដំណើរ | ចាស់ពីបុព្វេ |
| លោកគោរព ត | ទុកមកជាកេរ | ព្រោះបានរិះរេ |
| | រកឃើញខ្លឹមសារ។ | |
| រៀនបានមោះមុត | ដឹងថាព្រះពុទ្ធ | កើតលើលោកា |
| ត្រាស់ដឹងធម៌ពិត | មិនប្រឌិតការ | ប្រដៅសត្វា |
| | អោយដើរផ្លូវល្អ។ | |
| ចាស់បុព្វាចារ្យ | លោកមានបញ្ញា | ថ្លៃថ្លាបវរ |
| យល់ឃើញហេតុផល | គុណទោសខ្មៅ ស | ទើបលោកអំណរ |
| | កាន់យកពុទ្ធសាសន៍។ | |
| លោកមិនមែនល្ងង់ | ឆោតឆៅលិចលង់ | ឆាប់ជឿផ្តេសផ្តាស |
| គឺមានបញ្ញា | វិចារណ៍ច្បងច្បាស់ | ពេញលេញមិនខ្វះ |
| | ឃើញគ្រប់នាថន័យ។ | |
| យកទុកជាកេរ | អោយយើងគ្នាន់គ្នេរ | ល្អិតល្អន់ប្រពៃ |
| ដឹកនាំជីវិត | អោយផុតទុក្ខភ័យ | រកផ្លូវជោគជ័យ |
| | សុខក្នុងសង្គម។ | |
| យើងបច្ឆាជន | មិនត្រូវទំរន់ | អែនអនច្រិមច្រុម |
| ពុទ្ធសាសន៍ចែងច្បាស់ | បញ្ហាតូចធំ | ទុក្ខសោកសុខដុម |
| | កើតពីខ្លួនឯង។ | |
| អ្នកសាងទុច្ចរិត | នឹងទទួលពិត | បាបគ្រោះចំបែង |
| អ្នកកសាងល្អ | បានសុខចិញ្ចែង | ខ្លួនពឹងខ្លួនឯង |
| | ទើបបានថ្លៃថ្លា។ | |
| បាបកម្មយើងធ្វើ | បើនឹកមមើ | អាងលើនរណា |
| ទទួលជំនួស | អោយផុតទោសា | ជារឿងអនិច្ចា |
| | យល់ខុសស្រលះ។ | |

កុំគិតស្រួលពេក ព្យាយាមធ្មេចភ្នែក វិចារណ៍អោយច្បាស់
តាមតែគេថា ក្រែងវងអាម៉ាស់ ក្នុងនាមអ្នកខ្វះ
បញ្ញារិះគិត។

យើងជាកូនខ្មែរ ឆ្លៀវឆ្លាតខ្លាំងដែរ ខាងផ្នែកគំនិត
កុំស្ងួវហែអើ ទៅទាំងងងឹត ជំទែងក្អេងឫទ្ធី
ដូចសត្វកង្កែប។

ចង់ដឹងមានដង ត្រូវរៀនត្រាប់ត្រង ស្រាវជ្រាវបទបែប
មិនមែនព្រួលៗ ជួនខ្វាចឆៅឆែប ច្រឡំភ្លិនភ្លែប
វង្វេងសាសនា។

គិតមើលជាថ្មី គិតវែងកុំខ្លី ដោយប្រើបញ្ញា
អោយឃើញជម្រៅ ព្រះពុទ្ធសាសនា កាត់ក្តីសង្កា
ផុតភាន់ច្រឡំ។

កុំថាខ្ជិលគិត ក្រែងកប់គំនិត បាត់ភាពឧត្តម
ក្លាយទៅជានុយ គេផ្សាំងផ្សែផ្សំ នាយអាយឧបត្ថម្ភ
ងប់ងុលចិន្តា។

ខ្ញុំអ្នកសរសេរ មិនប្រាប់អោយរេ រើសអើងសាសនា
គ្រាន់តែអោយគិត ដោយញាណបញ្ញា យើងជាខេមរា
គួរណាស់ត្រូវដឹង។

បញ្ចប់កាព្យា នាមបុត្រភគវា លើកហត្ថរំពឹង
សូមគុណត្រៃរ័ត្ន អន្ទងព្រលឹង អោយខ្មែរចិត្តរឹង
មាំមានម្ចាស់ការ។

ទូទាំងបុរី ទាំងប្រុសទាំងស្រី សូមបានសុខា
មានចិត្តមាំមួន ស្ងួនជាតិខេមរា ថែពុទ្ធសាសនា
គង់គូដីខ្មែរ។✍

*(០៩ វិច្ឆិកា ២០០៣)*

*ភិក្ខុ ស្វាត សាលឿម*